ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

*ថ្ងៃអង្គារ ១២ កើត ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧*
*ប្រទេសអេហ្ស៊ីប, ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២៣*

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# ពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងហិរញ្ញប្បទានសហប្រតិបត្តិការ រវាងរាជរដ្ឋាភិបាលកម្ពុជា ជាមួយធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី (AIIB)

ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់បំផុតពីសម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងក្រោមការចាត់តាំងដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ឯកឧត្តម **ម៉ែន ធីរុត្ថ** អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានដឹកនាំគណៈប្រតិភូក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អញ្ជើញចូលរួមកិច្ចប្រជុំប្រចាំឆ្នាំលើកទី៨ នៃក្រុមប្រឹក្សាទេសាភិបាលធនាគារ AIIB ឆ្នាំ២០២៣ (8th Annual Meeting of the Board of Governors) កាលពីថ្ងៃទី២៥-២៦ ខែកញ្ញា ឆ្នាំ២០២៣ នៅទីក្រុង Sharm el-Sheikh នៃប្រទេសអេហ្ស៊ីប ក្រោមប្រធានបទ ***"កំណើនប្រកបដោយចីរភាពនៅក្នុងបរិការណ៍សេដ្ឋកិច្ចសាកលដ៏លំបាកមួយ (Sustainable Growth in a Challenging World)"*** ។

ឆ្លៀតក្នុងឱកាសនៃកិច្ចប្រជុំប្រចាំឆ្នាំលើកទី៨ នេះផងដែរ, នារសៀលថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២៣ ឯកឧត្តម **ម៉ែន ធីរុត្ថ** និងតំណាងធនាគារ AIIB ក៏បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់គម្រោងសុខភាពសត្វឆ្លងកាត់ព្រំដែន និងការជំរុញហេដ្ឋារចនាសម្ព័ន្ធខ្សែច្រវាក់តម្លៃសត្វ (Cross-border Livestock Health and Value Chain Infrastructure Improvement Project) ដែលមានទឹកប្រាក់សរុបចំនួន **៤៣ លានដុល្លារអាមេរិក** ដែលក្នុងនោះហិរញ្ញប្បទានសម្បទានពី AIIB ចំនួន **៣៣ លានដុល្លារអាមេរិក** និងហិរញ្ញប្បទានឥតសំណងពីមូលនិធិបង្ការ, ការត្រៀមខ្លួន និងការឆ្លើយតបជំងឺរាតត្បាត (Pandemic Prevention, Preparedness and Response Facility Trust Fund) ចំនួន **១០ លានដុល្លារអាមេរិក**។ គម្រោងនេះ ជាគម្រោងសហហិរញ្ញប្បទានរវាងធនាគារអភិវឌ្ឍន៍អាស៊ី (Asian Development Bank - ADB) និង AIIB ដែលមានទឹកប្រាក់សរុប ១២៨,៧៨ លានដុល្លារអាមេរិក ក្នុងនោះហិរញ្ញប្បទានសហប្រតិបត្តិការរបស់ ADB ចំនួន ៦២,៩ លានដុល្លារអាមេរិក និងថវិកាបដិភាគរាជរដ្ឋាភិបាលចំនួន ២២,៨៨ លានដុល្លារអាមេរិក ។

គម្រោងមានគោលបំណង÷ (១) លើកកម្ពស់ផលិតកម្ម និងការចិញ្ចឹមសត្វប្រកបដោយគុណភាព និងអនាម័យ, (២) ពង្រឹងសុវត្ថិភាពសុខភាពសត្វ និងមនុស្ស, បង្ការ និងទប់ស្កាត់ជំងឺឆ្លង និង (៣) លើកកម្ពស់ពាណិជ្ជកម្មសត្វឆ្លងកាត់ ព្រំដែន ក្នុងចំណោមប្រទេសនានានៃមហាអនុតំបន់ទន្លេមេគង្គ រួមមានកម្ពុជា, ឡាវ, វៀតណាម, ថៃ និងចិន។ គម្រោងនេះ នឹងអនុវត្តនៅក្នុងរាជធានី-ខេត្តគោលដៅ ចំនួន ០៦ រួមមាន÷ រាជធានីភ្នំពេញ, ខេត្តកំពង់ចាម, ខេត្តឧត្តរមានជ័យ, ខេត្តព្រៃវែង, ខេត្តសៀមរាប និងខេត្តតាកែវ។

ឯកឧត្តម **ប៉ែន ធីរុទ្ធ** បានរំលឹកឡើងវិញអំពីកិច្ចសហប្រតិបត្តិការរបស់ AIIB ដែលជាដៃគូអភិវឌ្ឍន៍ថ្មីមួយរបស់កម្ពុជា ហើយបានផ្តល់ហិរញ្ញប្បទានសម្បទានសម្រាប់គម្រោងដំបូងបំផុតនៅកម្ពុជា កាលពីឆ្នាំ២០២០ ក្រោមក្របខណ្ឌមូលនិធិស្តារវិបត្តិនៃជំងឺកូវីដ-១៩ (COVID-19 Crisis Recovery Facility)។ គម្រោងសុខភាពសត្វឆ្លងកាត់ព្រំដែន និងការជំរុញហេដ្ឋារចនាសម្ព័ន្ធខ្សែច្រវាក់តម្លៃសត្វ ជាគម្រោងហិរញ្ញប្បទានសម្បទានទី៣ របស់ AIIB ដែលនេះបានឆ្លុះបញ្ចាំងឱ្យឃើញអំពីការពង្រីក និងពង្រឹងកិច្ចសហប្រតិបត្តិការកាន់តែធំ និងរឹងមាំរវាងកម្ពុជា និង AIIB។

ឯកឧត្តម **ប៉ែន ធីរុទ្ធ** បានថ្លែងអំណរគុណចំពោះការផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការរបស់ AIIB ដែលបាននិងកំពុងរួមចំណែកយ៉ាងធំធេងក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងស្តារសេដ្ឋកិច្ចកម្ពុជាពីផលប៉ះពាល់នៃការរាតត្បាតជំងឺកូវីដ-១៩ ហើយ AIIB នឹងបន្តដើរតួនាទីជាដៃគូអភិវឌ្ឍន៍កាន់តែសំខាន់ក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងសេដ្ឋកិច្ចរបស់កម្ពុជានាពេលអនាគត ។